ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១*

# សេចក្តីជូនព័ត៌មាន

នាព្រឹកថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា **ឯកឧត្តម ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) បានទទួលជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយលោក **Andreas Zurbrugg** អនុប្រធានបេសកកម្មនៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា និងសហការី តាមរយៈប្រព័ន្ធបញ្ចូនរូបភាព និងសម្លេង ។ គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីពិភាក្សាអាទិភាពការងាររបស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍទ្វេភាគី, វឌ្ឍនភាពរបស់ផែនការអភិវឌ្ឍន៍ដើម្បីឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅកម្ពុជា ឆ្នាំ២០២០-២០២១ និងជម្រាបអំពីការផ្តួចផ្តើមកម្មវិធីអភិវឌ្ឍន៍សម្រាប់កម្ពុជានាពេលអនាគត ។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ **ឈៀង យ៉ាណារ៉ា** បានស្វាគមន៍យ៉ាងកក់ក្តៅ និងអបអរសាទរដល់លោក **Andreas Zurbrugg** ដែលទទួលបានការតែងតាំងជាអនុប្រធានបេសកកម្មថ្មីនៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា និងជាប្រធានទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិអូស្ត្រាលី ។ **ឯកឧត្តមរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដែលសម្រេចបានក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ដើម្បីឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅកម្ពុជា ឆ្នាំ២០២០-២០២១ ដែលសមិទ្ធផលទាំងនេះបានពង្រឹងភាពជាដៃគូ និងបានគាំទ្រដល់ការអភិវឌ្ឍរបស់កម្ពុជាប្រកបដោយចីរភាព និងបរិយាប័ន្ន ។

លោក **Andreas Zurbrugg** បានបង្ហាញអារម្មណ៍សោមនស្សរីករាយក្នុងការបំពេញបេសកកម្មរបស់លោកនៅប្រទេសកម្ពុជា និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដែលសម្រេចបានសមិទ្ធផលយ៉ាងធំធេងរហូតមកដល់បច្ចុប្បន្ន ។ ជាមួយគ្នានេះ លោក **Andreas** បានសម្តែងការកោតសរសើរចំពោះកិច្ចសហការដ៏ល្អក្នុងភាពជាដៃគូរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយរដ្ឋាភិបាលអូស្ត្រាលី ហើយបានប្តេជ្ញាបន្តពង្រឹងកិច្ចសហការ និងភាពជាដៃគូល្អនេះ ។

លោក **Andreas Zurbrugg** បានបញ្ជាក់អំពីការគាំទ្ររបស់អូស្ត្រាលីក្នុងកិច្ចអភិវឌ្ឍរបស់កម្ពុជាតាមរយៈការផ្តល់ហិរញ្ញប្បទានប្រមាណ ៦៦ លានដុល្លារអូស្ត្រាលី សម្រាប់ឆ្នាំ២០២១ ដើម្បីគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ដែលផ្តោតលើវិស័យសន្តិសុខសុខាភិបាល, ភាពធន់សេដ្ឋកិច្ច, កសិកម្ម និងអប់រំ ។ ទន្ទឹមនេះ លោក **Andreas** ក៏បានជម្រាបជូនអំពីការរៀបចំគម្រោងទ្វេភាគីថ្មី "ការអភិវឌ្ឍភាពធន់វិស័យសេដ្ឋកិច្ច" (Resilience Economic Development) មានទំហំហិរញ្ញប្បទានប្រមាណ ៩០ លានដុល្លារអូស្ត្រាលី សម្រាប់រយៈពេល ៥ឆ្នាំ ដែលនឹងត្រូវចាប់ផ្តើមចាប់ពីឆ្នាំ២០២២ នេះ រួមជាមួយលទ្ធភាពពន្យា ៣ឆ្នាំបន្ថែមទៀតផងដែរ ។ គម្រោងនេះ នឹងផ្តោតលើវិស័យអាទិភាព ៤ គឺ (១). វិស័យពាណិជ្ជកម្ម និងវិនិយោគ, (២). កសិកម្ម និងការកែច្នៃផលិតផលកសិកម្ម, (៣). ហេដ្ឋារចនាសម្ព័ន្ធ និង (៤). បរិយាប័ន្នសង្គម និងយេនឌ័រ ។

ជាការឆ្លើយតប ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ **ឈៀង យ៉ាណារ៉ា** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលអូស្ត្រាលីក្នុងការគាំទ្រកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេសអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ ។ **ឯកឧត្តមរដ្ឋមន្ត្រី** បានកោតសរសើរចំពោះការផ្តួចផ្តើមកម្មវិធីរបស់អូស្ត្រាលីដែលមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រនៃការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីកូវីដ-១៩ ដោយផ្តោតលើអភិក្រមការស្តារ, ការកែទម្រង់ និងភាពធន់ ។ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានកោតសរសើរចំពោះវឌ្ឍនភាពកម្មវិធី និងគម្រោងរបស់អូស្ត្រាលី ដូចជា កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i), កម្មវិធីខ្សែច្រវ៉ាក់តម្លៃកសិកម្មដំណាក់កាលទី២ (CAVAC II) ដែលឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ដើម្បីឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅកម្ពុជាឆ្នាំ២០២០-២០២២ ។

បន្ថែមពីនេះ លោក **Andreas** ក៏បានបញ្ជាក់អំពីការគាំទ្រហិរញ្ញប្បទានបន្ថែមរបស់អូស្ត្រាលីប្រមាណ ៣៥ លានដុល្លារអូស្ត្រាលី សម្រាប់គាំទ្រដល់ការបញ្ជារទិញវ៉ាក់សាំងកូវីដ-១៩ ចំនួនប្រមាណ ៣ លានដូស តាមរយៈអង្គការ UNICEF និងអង្គការសុខភាពពិភពលោក ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងផែនការចាក់វ៉ាក់សាំងជូនប្រជាជនក្នុងក្របខណ្ឌទូទាំងប្រទេស ។ ជាទីបញ្ចប់ ភាគីអូស្ត្រាលី ក៏បានបញ្ជាក់ពីការបន្តគាំទ្រហិរញ្ញប្បទានបន្ថែមលើកម្មវិធី ចំនួន ២ ផ្សេងទៀត គឺ កម្មវិធីលើកកម្ពស់គុណភាព និងសមភាពសុខាភិបាលដំណាក់កាលទី២ (H-EQIP II) ប្រមាណ ៣០ លានដុល្លារអូស្ត្រាលី និងគម្រោង Social Accountability Framework Project ដំណាក់កាលទី ២ (ISAF II) ប្រមាណ ១៥ លានដុល្លារអូស្ត្រាលី សម្រាប់រយៈពេល ៥ឆ្នាំខាងមុខ ។

ជាកិច្ចបញ្ចប់ **ឯកឧត្តមរដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនអូស្ត្រាលីសម្រាប់ការគាំទ្រដល់កិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេសការប្តេជ្ញារបស់អូស្ត្រាលីលើការផ្តល់វ៉ាក់សាំងដែលមានសុវត្ថិភាព និងប្រសិទ្ធភាពជូនប្រជាពលរដ្ឋកម្ពុជា ។

---------------